ROYAL RAILWAY

# របាយការណ៍ប្រចាំត្រីមាសទី១

## គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣

## រ៉ូយ៉ាល់ រេលវេ ម.ក.

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | | ត្រីមាសទី១ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១៤៨.៩៦៩ | ១៥៤.៨៣៣ | ៣១.៣៩០ |
| បំណុលសរុប | | ១៥៥.៦៣៧ | ១៦៤.១៧៧ | ២៣.៨៥៨ |
| មូលធនសរុប | | (៦.៦៦៧) | (៩.៣៤៤) | ៧.៥៣២ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | | **ត្រីមាសទី១ ឆ្នាំ២០២៣** | **ត្រីមាសទី១ ឆ្នាំ២០២២** | **ត្រីមាសទី១ ឆ្នាំ២០២១** |
| ចំណូលសរុប | | ១២.៧៣៦ | ១២.៧២១ | ១០.៨៩៣ |
| ខាតមុនបង់ពន្ធ | | ២.៥៥៣ | (១.៥៥៥) | ៥៣៦ |
| ខាតសុទ្ធក្នុងការិយបរិច្ឆេទ | | ២.៥៥៣ | (១.៥៥៥) | ៥៣៦ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ២.៦៧៧ | (១.៥៩៥) | ៥៣៤ |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី១ ឆ្នាំ២០២៣** | **ឆ្នាំ២០២២** | **ឆ្នាំ២០២១** |
| អនុបាតសាធនភាព | | ៣៦% | -១១៨% | ១៦% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ៥.៦៩ | ៤.៥០ | ០.២២ |
| | អនុបាតចរន្តលឿន | ៥.៦៣ | ៤.៤៦ | ០.១៩ |
| **អនុបាតចំណេញភាព** | | **ត្រីមាសទី១ ឆ្នាំ២០២៣** | **ត្រីមាសទី១ ឆ្នាំ២០២២** | **ត្រីមាសទី១ ឆ្នាំ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម[៩] | | ១,៧១% | -៤,៦៩% | ១,៦០% |
| អនុបាតចំណេញធៀបនឹងមូលធន[៩] | | -៣៨,២៩% | -២៦,២០% | -២,៧៨% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | (០.៩២) | ១១.៦៣ | (២.៨៣) |
| អនុបាតគម្លាតចំណេញដុល | | -១២,៣១% | -០,១៩% | ១៣,៩២% |
| អនុបាតគម្លាតចំណេញភាព | | ២០,០៤% | -១២,២៣% | ៤,៩២% |

[៩] អនុបាតត្រូវបានគណនាលើប្រាក់ចំណេញសុទ្ធរយៈពេល៣ខែ គិតចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប


















# ក្រុមប្រឹក្សាភិបាល



អ្នកឧកញ៉ា គិត ម៉េង
ប្រធានក្រុមប្រឹក្សាភិបាល



លោក Raymond Thornton Yager
អភិបាល



លោក William Mark Hanna
អភិបាល



លោក Paul Clement
អភិបាល



លោក Lun Yeng
អភិបាល

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

យើងខ្ញុំមានក្តីសោមនស្សរីករាយក្នុងការបង្ហាញនូវលទ្ធផលហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ ម.ក. (រ៉ូយ៉ាល់ រេលវេ) ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ ស្របតាមតម្រូវការរបស់និយតករមូលបត្រកម្ពុជា (ន.ម.ក)។

ដោយសាររាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវយុទ្ធសាស្រ្ត "រស់នៅជាមួយជំងឺកូវីដ-១៩" នៅចុងឆ្នាំ ២០២១ បន្ទាប់ពីទទួលបានជោគជ័យនៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ យ៉ាងឆាប់រហ័ស និងបានច្រើនទៅដល់ប្រជាជនក្នុងប្រទេសនោះ ដែលជាកត្តាមួយធ្វើឲ្យសេដ្ឋកិច្ចរបស់កម្ពុជាមានការងើបឡើងវិញយ៉ាងល្អក្នុងរយៈពេលរាយការណ៍។ ធនាគារពិភពលោកព្យាករណ៍ពីកំណើនសេដ្ឋកិច្ច ៤,៨ ភាគរយ ក្នុងឆ្នាំ ២០២២ ដោយសារការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ និងភាពធន់នៃឧស្សាហកម្មកាត់ដេរ ការដឹកជញ្ជូន និងការនាំចេញស្បៀកជើង។ ភ្ញៀវអន្តរជាតិសរុបបានកើនឡើងជាលំដាប់។ ទំនុកចិត្តទៅលើអាជីវកម្ម និងអ្នកប្រើប្រាស់ បានកើនឡើង ហើយការវិនិយោគទាំងក្នុង និងក្រៅប្រទេសបានកើនឡើង។ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ៥,២ ភាគរយនៅក្នុង ឆ្នាំ២០២៣។ ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាទទួលរងការប៉ះពាល់ជាពិសេសចំពោះការកើនឡើងអតិផរណា ការកំណើនសេដ្ឋកិច្ចពិភពលោកយឺតការថយចុះនៃការផ្គត់ផ្គង់ថាមពល និងអត្រាការប្រាក់មានការកើនឡើង។

ចំពេលបរិយាកាសធុរកិច្ចមានការតានតឹង រ៉ូយ៉ាល់ រេលវេ បានដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព តាមរយៈ ការស្វែងរកអតិថិជនថ្មីសម្រាប់សេវាកម្មដឹកជញ្ជូនទំនិញជាមួយនឹងតម្លៃសមរម្យបំផុត ដើម្បីសមជាមួយនឹងការផ្លាស់ ប្តូរបរិយាកាសសេដ្ឋកិច្ច។

នៅក្នុងត្រីមាសនេះ រ៉ូយ៉ាល់ រេលវេ បានផ្សព្វផ្សាយយ៉ាងសកម្មនូវសេវាកម្មរថភ្លើងដឹកអ្នកដំណើរ ដែលបង្កើតគំនិតសម្រាប់ដំណើរកំសាន្តសម្រាប់ថ្ងៃឈប់សម្រាករបស់ប្រជាជនកម្ពុជា ក៏ដូចជាការធ្វើដំណើរដ៏គួរឲ្យចងចាំមួយទៅកាន់ភាគខាងជើង និងខាងត្បូងនៃប្រទេសតាមរយៈការធ្វើដំណើរតាមរថភ្លើង។

ជាផ្នែកមួយនៃការលើកទឹកចិត្តក្នុងការចុះបញ្ជីមូលបត្រ ក្រុមហ៊ុនបានដាក់លិខិតទៅ ន.ម.ក. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ដើម្បីស្នើសុំការអនុគ្រោះបំណុលពន្ធទាំងស្រុង។ នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រុមហ៊ុនបានទទួល សេចក្តីជូនដំណឹងពី ន.ម.ក ថាការស្នើសុំត្រូវបានដាក់ជូន អ.ព.ដ។ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ សំណើលើកលែងពន្ធនេះត្រូវបានផ្តល់ឲ្យក្រុមហ៊ុនដោយ អ.ព.ដ ដែលមានចំនួន ១.៨៤២.៩៧៣ ដុល្លារអាមេរិក។ នេះជាព្រឹត្តិការណ៍សំខាន់មួយទៀតមកទល់ពេលនេះ។

ត្រីមាសទី១ ឆ្នាំ២០២៣ នេះក្រុមហ៊ុនមាន ទ្រព្យសកម្មសរុបមានចំនួន ១៤៨.៩៦៩ លានរៀល ថយចុះ -៤% បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២។ ប្រាក់ចំណូលសរុបមានចំនួន ១២.៧៣៦ លានរៀល កើនឡើង ០,១២ % បើធៀបនឹងត្រីមាសដូចគ្នានៃឆ្នាំ២០២២។ ដោយសារតែការកើនឡើងនៃវិស័យដឹកជញ្ជូនតាមផ្លូវដែកទៅកាន់ខ្សែភាគខាងជើង និងក៏ដូចជាការកើនឡើងនៃប្រាក់ចំណូលនៃការដឹកជញ្ជូនអ្នកដំណើរ ទៅកាន់ត្រីមាសទី១ នៃឆ្នាំនេះ។ មូលធនសរុបក៏បានកើនឡើង និងឈានដល់ -៦.៦៦៧ លានរៀលក្នុងរយៈពេល ដែលបានរាយការណ៍។

ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុនមានទំនុកចិត្តថា ការដឹកនាំ យុទ្ធសាស្រ្ត និងធនធានមនុស្ស របស់ រ៉ូយ៉ាល់ រេលវេ នឹងធ្វើឲ្យ រ៉ូយ៉ាល់ រេលវេ បន្តការរីកចំរើនរបស់ខ្លួនសម្រាប់អ្នកវិនិយោគទាំងអស់។

ក្នុងនាមក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងបុគ្គលិករបស់ រ៉ូយ៉ាល់ រេលវេ ចំពោះការខិតខំប្រឹងប្រែង ប្រកបដោយភាពស្វាហាប់ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រីកអាជីវកម្ម ជាមួយនឹងការរីកចំរើនរបស់អតិថិជនរបស់យើងខ្ញុំប្រកបដោយសុខដុមរមនា។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាភិបាល ម្ចាស់ភាគហ៊ុន អតិថិជន រាជរដ្ឋាភិបាលកម្ពុជា និងជាពិសេសនិយ័តករមូលបត្រកម្ពុជា (ន.ម.ក) និងផ្សារមូលបត្រកម្ពុជា (ផ.ម.ក) សម្រាប់ការគាំទ្រ និងដំបូន្មានជាប្រចាំ។

ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣

អ្នកឧកញ៉ា គិត ម៉េង

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ....... ii

ក្រុមប្រឹក្សាភិបាល ....... iii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ....... iv

ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ....... ១

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ....... ១

ខ. លក្ខណៈនៃធុរកិច្ច ....... ២

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ....... ២

ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ....... ៣

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ....... ៣

ខ. រចនាសម្ព័ន្ធចំណូល ....... ៣

ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ ....... ៥

ផ្នែកទី ៤ - ការពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង ....... ៦

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ....... ៦

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ....... ៩

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ....... ១០

ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ....... ១០

ង. ផលប៉ះពាល់នៃអតិផរណា ....... ១១

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ....... ១១

ផ្នែកទី ៥ - ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន ....... ១២

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ....... ១៣

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | រ៉ូយ៉ាល់ រេលវេ ម.ក. |
| ជាអក្សរឡាតាំង | Royal Railway Plc. |
| លេខកូដសស្តង់ដារ | KH២០០០១៩១CA៤<br>KH២០០០១៩២CC៨<br>KH២០០០១៩៣CC៦ |
| ទីស្នាក់ការ | ស្ថានីយ៍រថភ្លើងភ្នំពេញ មហាវិថីសហព័ន្ធរុស្សី<br>សង្កាត់ស្រះចក ខណ្ឌដូនពេញ<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៩៩២ ៣៧៩ |
| លេខទូរសារ | +៨៥៥ ២៣ ៩៩២ ៣៥៣ |
| វេបសាយត៍ | royal-railway.com |
| អ៊ីម៉ែល | admin@រ៉ូយ៉ាល់ រេលវេambodia.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៨៥០៤ កាលបរិច្ឆេទ៖ ថ្ងៃទី០៦ ខែតុលាឆ្នាំ២០១៥ |
| សេចក្តីសម្រេចអនុញ្ញាតនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ២០២/២២ ន.ម.ក/ស.ស.រ កាលបរិច្ឆេទ៖ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២<br>២៧៣/២២ ន.ម.ក/ស.ស.រ កាលបរិច្ឆេទ៖ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក John Guiry |

## ខ. លក្ខណៈនៃធុរកិច្ច

ផ្លូវដែកនៅកម្ពុជាមានពីរខ្សែ គឺខ្សែខាងជើង និងខ្សែខាងត្បូង ដែលមានប្រវែងសរុប ៦៥០ គីឡូម៉ែត្រ។ ខ្សែខាងជើងមានប្រវែងសរុប ៣៨៦គីឡូម៉ែត្រ ពីភ្នំពេញទៅក្រុងប៉ោយប៉ែត (ព្រំដែនកម្ពុជា-ថៃ)។ ខ្សែខាងត្បូងមានប្រវែងសរុប ២៦៤គីឡូម៉ែត្រ។

សេវាកម្មសំខាន់ៗ របស់ រ៉ូយ៉ាល់ រេលវេ រួមមានសេវាកម្មដឹកជញ្ជូន (ប្រេងឥន្ធនៈ ស៊ីម៉ងត៍ ថ្ម អង្ករ ។ល។) ការដឹកជញ្ជូនឥន្ធនៈមានចំនួនច្រើន ជាងការដឹកជញ្ជូនតាមកុងតឺន័រ (សម្លៀកបំពាក់ រថយន្ត អង្ករ កៅស៊ូ ស្ករ។ល។) មានឃ្លាំងសម្រាប់ជួលក្នុងការស្តុកទំនិញ និង សេវាកម្មរត់ឯកសារគយ និងពន្ធគយ។

សូមមើលព័ត៌មានខាងក្រោមសម្រាប់ចំណូលលម្អិតនៃសេវាកម្ម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល | ដុល្លារអាមេរិក | សមមូលពាន់រៀល |
| ផ្លូវទិសខាងត្បូង៖ | | | | |
| ការដឹកទំនិញតាមផ្លូវដែក | ១.៤៥១.១១០ | ៥.៩២៦.៣៣៤ | ១.៨៦២.៣០៥ | ៧.៥៦៦.៥៤៥ |
| សេវាបន្ថែមផ្សេងៗតាមទូររថភ្លើង | ៩៨.៦៦៣ | ៤០២.៩៤០ | ១៧៤.៩២៣ | ៧១០.៧១២ |
| ថ្លៃសំបុត្ររថភ្លើងពីអ្នកដំណើរ | ១៥៨.៤៣០ | ៦៤៧.០២៨ | ២៣.៦៤១ | ៩៦.០៥៣ |
| ការដឹកជញ្ជូន | ៩.៦៧៥ | ៣៩.៥១៣ | ១៣.៩១១ | ៥៦.៥២០ |
| ប្រាក់ចំណូលផ្សេងៗ | - | - | ១៧.៤៥១ | ៧០.៩០៣ |
| | ១.៧១៧.៨៧៨ | ៧.០១៥.៨១៥ | ២.០៩២.២៣១ | ៨.៥០០.៧៣៣ |
| ផ្លូវទិសខាងជើង៖ | | | | |
| ការដឹកទំនិញតាមផ្លូវដែក | ៩០៥.៣០៩ | ៣.៦៩៧.២៨២ | ៨៨៣.៨៥០ | ៣.៥៩១.០៨៤ |
| ថ្លៃសំបុត្ររថភ្លើងពីអ្នកដំណើរ | ៥៧.០២៦ | ២៣២.៨៩៤ | - | - |
| សេវាបន្ថែមផ្សេងៗតាមទូររថភ្លើង | ១២.០២៩ | ៤៩.១២៦ | - | - |
| ការដឹកជញ្ជូន | - | - | - | - |
| ប្រាក់ចំណូលផ្សេងៗ | ២.២៦៥ | ៩.២៥០ | - | - |
| | ៩៧៦.៦២៩ | ៣.៩៨៨.៥៥២ | ៨៨៣.៨៥០ | ៣.៥៩១.០៨៤ |
| | ២.៦៩៤.៥០៧ | ១១.០០៤.៣៦៧ | ២.៩៧៦.០៨១ | ១២.០៩១.៨១៧ |

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ជាផ្នែកមួយនៃការលើកទឹកចិត្តក្នុងការចុះបញ្ជីមូលបត្រ ក្រុមហ៊ុនបានដាក់លិខិតទៅ ន.ម.ក. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ដើម្បីស្នើសុំការអនុគ្រោះបំណុលពន្ធទាំងស្រុង។ នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រុមហ៊ុនបានទទួល សេចក្តីជូនដំណឹងពី ន.ម.ក ថាការស្នើសុំត្រូវបានដាក់ជូន អ.ព.ដ។ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ សំណើលើកលែងពន្ធនេះត្រូវបានផ្តល់ឲ្យ ក្រុមហ៊ុនដោយ អ.ព.ដ ដែលមានចំនួន ១.៨៤២.៩៧៣ ដុល្លារអាមេរិក។ ក្រុមហ៊ុនបានធ្វើការកត់ត្រានៅក្នុងបញ្ជីគណនីរបស់ខ្លួនរួចរាល់ទៅលើសំណើលើកលែងពន្ធនេះ។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

| លទ្ធផលសំខាន់ៗសម្រេចបាន | ខែមីនា ឆ្នាំ២០២៣ | ខែមីនា ឆ្នាំ២០២២ | ខែមីនា ឆ្នាំ២០២១ |
|---|---|---|---|
| *សេវាកម្មដឹកជញ្ជូនគិតជាតោន* | | | |
| ថ្ម | ២.០៩១ | ២.២១៤ | ២.៦៤៦ |
| ស៊ីម៉ងត៍ | ៥.៩៥០ | ២.៥៩៦ | ៤.៩៤៦ |
| ធ្យូងថ្ម | - | - | - |
| កុងតឺន័រ | ១៤១.៦៧៩ | ១៥៦.៨៨៤ | ១២៧.៤៨៩ |
| ម៉ាស៊ូត | ៩៨.៨៥៣ | ១១៤.៨៤១ | ៩៩.៦២៩ |
| ដី | - | - | - |
| សាំង | ២៣.៦៦៧ | ២០.១០៣ | ២១.៥៣៤ |
| កំបោរ | ៥៧៦ | - | - |
| រថយន្ត | ៥៥៨ | - | - |
| **ប្រាក់ចំណូលសរុប (គិតជាលានរៀល)** | **១០.១២៤** | **១១.៩៩៦** | **៩.៩៩៤** |
| | | | |
| *សេវាកម្មរថភ្លើងអ្នកដំណើរ* | | | |
| *ចំនួនអ្នកដំណើរ* | ២០.៨២១ | ៣.៥៤៤ | ៣.៥៤៦ |
| **ប្រាក់ចំណូលសរុប (គិតជាលានរៀល)** | **៨៨០** | **៩៦** | **១០៧** |

## ខ. រចនាសម្ព័ន្ធចំណូល

| | ត្រីមាសទី៤ ឆ្នាំ២០២២ | | ត្រីមាសទី៤ ឆ្នាំ២០២១ | | ត្រីមាសទី៤ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) |
| ប្រភពចំណូល | | | | | | |
| ផ្លូវទិសខាងត្បូង៖ | | | | | | |
| ការដឹកទំនិញតាមផ្លូវដែក | ៥.៩២៦ | ៤៦,៥៣% | ៧.៥៦៧ | ៥៩,៤៨% | ៤.៧១១ | ៤៣,២៥% |
| សេវាបន្ថែមផ្សេងៗតាមទូររថភ្លើង | ៤០៣ | ៣,១៦% | ៧១១ | ៥,៥៩% | ៤៨៨ | ៤,៤៨% |
| ថ្លៃសំបុត្ររថភ្លើងពីអ្នកដំណើរ | ៦៤៧ | ៥,០៨% | ៩៦ | ០,៧៦% | ១០៧ | ០,៩៨% |
| ការដឹកជញ្ជូន | ៤០ | ០,៣១% | ៥៧ | ០,៤៤% | ២៤ | ០,២២% |
| ប្រាក់ចំណូលផ្សេងៗ | - | ០,០០% | ៧១ | ០,៥៦% | - | ០,០០% |
| | ៧.០១៦ | ៥៥,០៩% | ៨.៥០១ | ៦៦,៨៣% | ៥.៣៣០ | ៤៨,៩៣% |

## ខ. រចនាសម្ព័ន្ធចំណូល (ត)

| | ត្រីមាសទី១ ឆ្នាំ២០២៣ | | ត្រីមាសទី១ ឆ្នាំ២០២២ | | ត្រីមាសទី១ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|
| | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) |
| ផ្លូវទិសខាងជើង៖ | | | | | | |
| ការដឹកទំនិញតាមផ្លូវដែក | ៣.៦៩៧ | ២៩,០៣% | ៣.៥៩១ | ២៨,២៣% | ៤.៧៧០ | ៤៣,៧៩% |
| ថ្លៃសំបុត្ររថភ្លើងពីអ្នកដំណើរ | ២៣៣ | ១,៨៣% | - | 0,00% | - | 0,00% |
| សេវាបន្ថែមផ្សេងៗតាមទូររថភ្លើង | ៤៩ | 0,៣៩% | - | 0,00% | ២ | 0,0២% |
| ការដឹកជញ្ជូន | - | 0,00% | - | 0,00% | - | 0,00% |
| ប្រាក់ចំណូលផ្សេងៗ | ៩ | 0,0៧% | - | 0,00% | - | 0,00% |
| | ៣.៩៨៩ | ៣១,៣២% | ៣.៥៩១ | ២៨,២៣% | ៤.៧៧១ | ៤៣,៨0% |
| ចំណូលផ្សេងៗពីប្រតិបត្តិការ | | | | | | |
| ចំណូលពីការជួលឃ្លាំង | ៨២២ | ៦,៤៥% | ៦២៦ | ៤,៩២% | ៧៨៨ | ៧,២៤% |
| ចំណូលហិរញ្ញវត្ថុ | ៣៩៨ | ៣,១២% | 0 | 0,00% | 0 | 0,00% |
| ចំណូលផ្សេងៗ | ៥១១ | ៤,0១% | ៣ | 0,0២% | ២ | 0,0២% |
| | ១.៧៣១ | ១៣,៥៩% | ៦២៩ | ៤,៩៤% | ៧៩១ | ៧,២៦% |
| ប្រាក់ចំណូលសរុប | ១២.៧៣៦ | ១00,00% | ១២.៧២១ | ១00,00% | ១0.៨៩៣ | ១00,00% |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធនៃរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យដូចមានជូនភ្ជាប់។

# ផ្នែកទី ៤ - ការពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគ របស់គណៈគ្រប់គ្រងរបស់ រ៉ូយ៉ាល់ រេលវេ អំពីលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ដែលត្រូវបានពិនិត្យដោយ ក្រុមហ៊ុនសវនករឯករាជ្យ ខេ ភី អឹម ជី ខេមបូឌា (សវនករឯករាជ្យ)។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS)។ ក្រុមការងារគណៈគ្រប់គ្រងបានពិភាក្សា និងវិភាគតែផ្នែកសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់រ៉ូយ៉ាល់ រេលវេ ។

## ក. និន្នាការទូទៅនៃប្រតិបត្តិការ

### ១. វិភាគចំណូល

រ៉ូយ៉ាល់ រេលវេ បង្កើតប្រាក់ចំណូលពីប្រភពធំៗចំនួនបីដូចខាងក្រោម៖

- ប្រាក់ចំណូលទទួលបានពីការដឹកជញ្ជូនតាមផ្លូវដែក៖ សេវាកម្មដឹកជញ្ជូនដែលផ្តល់ជូនអតិថិជនទាំងខ្សែទិសខាងជើង និងខ្សែទិសខាងត្បូង។
- ប្រាក់ចំនូលនៃសេវាកម្មបន្ថែមដែលទាក់ទងនឹងរថភ្លើង៖ ប្រាក់ចំណូលពីថ្លៃលើកដាក់លើកុងតឺន័រ ការស្តែនកុងតឺន័រផ្ទាល់ខ្លួន សេវាលើការរត់ឯកសារសម្រាប់អតិថិជន និងថ្លៃទទួលទុកកុងតឺន័រ។
- ថ្លៃឈ្នួលដឹកអ្នកដំណើរ៖ សេវាដឹកអ្នកដំណើរតាមខ្សែរថភ្លើងភាគខាងត្បូង ដូចជាគោលដៅពីរាជធានីភ្នំពេញទៅស្ថានីយ៍តាកែវ ស្ថានីយ៍កែប ស្ថានីយ៍កំពត ស្ថានីយ៍ព្រះសីហនុ និងខ្សែខាងជើងពីរាជធានីទៅស្ថានីយ៍ពោធិសាត់ ស្ថានីយ៍បាត់ដំបង និងស្ថានីយ៍ប៉ោយប៉ែត។
- សេវាកម្មឃ្លាំងសម្រាប់ជួលដែលក្រុមហ៊ុនទទួលបានប្រាក់ចំណូលផងដែរ។

### ២. ការវិភាគចំណូលតាមផ្នែក

| ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២៣ ទឹកប្រាក់សរុប (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២៣ ភាគរយ (%) | ត្រីមាសទី១ ឆ្នាំ២០២២ ទឹកប្រាក់សរុប (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២២ ភាគរយ (%) |
|---|---|---|---|---|
| ផ្លូវទិសខាងត្បូង៖ | | | | |
| ការដឹកទំនិញតាមផ្លូវដែក | ៥.៩២៦ | ៤៦,៥៣% | ៧.៥៦៧ | ៥៩,៤៨% |
| សេវាបន្ថែមផ្សេងៗតាមទូររថភ្លើង | ៤០៣ | ៣,១៦% | ៧១១ | ៥,៥៩% |
| ថ្លៃសំបុត្ររថភ្លើងពីអ្នកដំណើរ | ៦៤៧ | ៥,០៨% | ៩៦ | ០,៧៦% |
| ការដឹកជញ្ជូន | ៤០ | ០,៣១% | ៥៧ | ០,៤៤% |
| ប្រាក់ចំណូលផ្សេងៗ | - | ០,០០% | ៧១ | ០,៥៦% |
| | ៧.០១៦ | ៥៥,០៩% | ៨.៥០១ | ៦៦,៨៣% |

## ក. និដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ២. ការវិភាគចំណូលតាមផ្នែក (ត)

| ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២៣ ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) | ត្រីមាសទី១ ឆ្នាំ២០២២ ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) |
|---|---|---|---|---|
| ផ្លូវទិសខាងជើង៖ | | | | |
| ការដឹកទំនិញតាមផ្លូវដែក | ៣.៦៩៧ | ២៩,០៣% | ៣.៥៩១ | ២៨,២៣% |
| ថ្លៃសំបុត្ររថភ្លើងពីអ្នកដំណើរ | ២៣៣ | ១,៨៣% | - | 0,00% |
| សេវាបន្ថែមផ្សេងៗតាមទូររថភ្លើង | ៤៩ | 0,៣៩% | - | 0,00% |
| ការដឹកជញ្ជូន | - | 0,00% | - | 0,00% |
| ប្រាក់ចំណូលផ្សេងៗ | ៩ | 0,0៧% | - | 0,00% |
| | ៣.៩៨៩ | ៣១,៣២% | ៣.៥៩១ | ២៨,២៣% |
| ប្រាក់ចំណូលសរុប | ១១.00៤ | ៨៦,៤១% | ១២.0៩២ | ៩៥,0៦% |

ប្រាក់ចំណូលលើការដឹកជញ្ជូនតាមផ្លូវដែកគឺជាប្រភពចំណូលដ៏សំខាន់សម្រាប់ រ៉ូយ៉ាល់ រេលវេ។ នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០២៣ ប្រាក់ចំណូលដឹកជញ្ជូនផ្លូវដែកស្មើនឹង ៧៥,៥៦% នៃប្រាក់ចំណូលសរុប។ បើប្រៀបធៀបទៅនឹងឆ្នាំមុនជាមួយនឹង ត្រីមាសដូចគ្នានេះ ពុំមានការប្រែប្រួលច្រើននៃប្រាក់ចំណូលរបស់ រ៉ូយ៉ាល់ រេលវេ នោះទេ លើកលែងតែសេវារថភ្លើងអ្នកដំណើរទៅទិសខាងជើងដែលមានការកើនឡើងខ្ពស់ដោយសារតែក្រុមហ៊ុនចាប់ផ្តើមដំណើរការសេវាកម្មនេះជារៀងរាល់ថ្ងៃ។

### ៣. ការវិភាគគម្លាតខាតដុល

ប្រាក់ចំណេញដុលមិនបង្ហាញក្នុងទម្រង់នៃរបាយការណ៍នៃប្រាក់ចំណូលសរុបដែលរៀបចំដោយ រ៉ូយ៉ាល់ រេលវេ ទេ។ ទោះជាយ៉ាងណាក៏ដោយ វាបង្ហាញពីប្រាក់ចំណូលសុទ្ធដែលមកពីប្រាក់ចំណូលតិចជាងតម្លៃនៃការលក់ដែលត្រូវបានចង្អុលបង្ហាញនៅក្នុងផ្នែកទី ៤ - ប្រាក់ចំណេញ / (ការបាត់បង់) មុនពេលការវិភាគពន្ធ។

## ៤. ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ/(ខាត) មុនបង់ពន្ធ | ត្រីមាសទី១ ឆ្នាំ២០២៣ ទឹកប្រាក់សរុប (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២២ ទឹកប្រាក់សរុប (លានរៀល) | លម្អៀង ទឹកប្រាក់សរុប (លានរៀល) | លម្អៀង (ភាគរយ) |
|---|---|---|---|---|
| ចំណូល | ១១.០០៥ | ១២.០៩២ | (១.០៨៧) | -៨,៩៩% |
| ថ្លៃដើមសេវាកម្ម | (១២.៥៧២) | (១២.១១៦) | (៤៥៦) | ៣,៧៦% |
| ប្រាក់ខាតដុល | (១.៥៦៧) | (២៤) | (១.៥៤៣) | ៦៤៤១,៣០% |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ១.៧៣១ | ៦២៩ | ១.១០២ | ១៧៥,២១% |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | ៥.២១៧ | (១.៨៥៥) | ៧.០៧២ | -៣៨១,៣១% |
| ការកត់ត្រឡប់វិញ/(សំវិធានធន) សម្រាប់ ការខាតបង់ឱនភាពនៃតម្លៃ | ៨៣ | ៤៥ | ១២៧ | -២៨៥,៣៩% |
| ចំណាយពន្ធអប្បបរមា | (១២៧) | (១២៨) | ១ | -០.៥៧% |
| ប្រាក់ខាតពីប្រតិបត្តិការ | ៥.៣៣៧ | (១.៤២២) | ៦.៧៥៩ | -៤៧៥,៤២% |
| ចំណាយហិរញ្ញប្បទាន | (២.៧៨៤) | (១៣៤) | (២.៦៥១) | ១៩៨១,០៣% |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ២.៥៥៣ | (១.៥៥៥) | ៤.១០៨ | ២៦៤,១២% |

នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០២៣ ប្រាក់ចំណេញខាតមុនដកពន្ធ បានកើនឡើងចំនួន៤.១០៨ លានរៀល ស្មើនឹង ២៦៤,១២% បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នាក្នុងឆ្នាំ ២០២២។ ការកើនឡើងនៃប្រាក់ចំណេញសម្រាប់ត្រីមាសនេះភាគច្រើនដោយសារតែការលើកលែងបំណុលពន្ធពី អ.ព.ដ ។

## ៥. ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ/(ខាត) ក្រោយបង់ពន្ធ | ត្រីមាសទី១ ឆ្នាំ២០២៣ ទឹកប្រាក់សរុប (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២២ ទឹកប្រាក់សរុប (លានរៀល) | លម្អៀង ទឹកប្រាក់សរុប (លានរៀល) | លម្អៀង (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ២.៥៥៣ | (១.៥៥៥) | ៤.១០៨ | ២៦៤,១២% |
| ចំណាយពន្ធលើប្រាក់ចំណេញ | - | - | - | 0% |
| **ប្រាក់ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ** | ២.៥៥៣ | (១.៥៥៥) | ៤.១០៨ | ២៦៤,១២% |

ពន្ធលើប្រាក់ចំណូលត្រូវបានគណនាលើការបាត់បង់ជាប់ពន្ធលើអត្រាពន្ធ២០% ។ ដោយសារ រ៉ូយ៉ាល់ រេលវេ មានខាតបង់មុនពន្ធលើប្រាក់ចំណូលពីឆ្នាំមុនដែលធ្វើឲ្យមាន បង្គពន្ធខាតបង់ប្រើប្រាស់សម្រាប់ទូទាត់ពន្ធលើប្រាក់ចំណេញក្នុងអំឡុង ត្រីមាសទី១ ឆ្នាំ២០២៣ នេះ ការចំណាយលើពន្ធលើប្រាក់ចំណេញនឹងគណនាម្តងទៀតនៅពេលឆ្នាំបញ្ចប់ ដូច្នេះរ៉ូយ៉ាល់ រេលវេ បានបង់ពន្ធអប្បបរមាលើប្រាក់ចំណូល។

### ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ត្រីមាសទី៤ ឆ្នាំ២០២២ ទឹកប្រាក់សរុប (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២១ ទឹកប្រាក់សរុប (លានរៀល) | លម្អៀង ទឹកប្រាក់សរុប (លានរៀល) | លម្អៀង (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ២.៥៥៣ | (១.៥៥៥) | ៤.១០៨ | ២៦៤,១២% |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ១២៤ | (៣៩) | ១៦៤ | ៤១៥.៣៦% |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ២.៦៧៧ | (១.៥៩៥) | ៤.២៧២ | ២៦៧.៨៦% |

ធាតុនៃលទ្ធផលលម្អិតផ្សេងៗរួមបញ្ចូលតែភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ដែលបានមកពីទ្រព្យសកម្ម និងបំណុលត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់ចុងគ្រានាការិយបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ចំណែកឯចំណូល និងចំណាយ ដែលបានបង្ហាញក្នុងរបាយការណ៍លទ្ធផលពេញលេញ និងលំហូរសាច់ប្រាក់ ត្រូវបានប្រែសម្រួលដោយប្រើអត្រាមធ្យមក្នុងការិយបរិច្ឆេទខណៈពេលដែលដើមទុនត្រូវបានប្រែសម្រួលតាមអត្រាប្រវត្តិ ១ដុល្លារអាមេរិក ស្មើនឹង៤.០០០រៀល។

### ៧. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ផលប៉ះពាល់សំខាន់ចំពោះលក្ខខណ្ឌហិរញ្ញវត្ថុ និងលទ្ធផលនៃ រ៉ូយ៉ាល់ រេលវេ សម្រាប់ត្រីមាសដំបូងនៃឆ្នាំ២០២៣ នេះគឺដោយសារការកើនឡើងនៃថ្លៃសេវា ដែលសំខាន់ជាងគេនោះគឺតម្លៃប្រេងឥន្ធនៈ និងក៏ដូចជាការកើនឡើងនៃសំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃ នៃគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ រួមទាំងសមតុល្យនៅធនាគារ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគលើស្ថានភាពតម្រូវការ និងការផ្គត់ផ្គង់

រ៉ូយ៉ាល់ រេលវេ គឺជាក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនតាមផ្លូវដែកតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលផ្តល់ជូននូវការដឹកជញ្ជូនទំនិញជាច្រើនមុខទូទាំងប្រទេសប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ដោយសារផ្លូវដែកអាចដឹកជញ្ជូនទំនិញបានក្នុងបរិមាណច្រើនបើធៀបនឹងការដឹកជញ្ជូនតាមផ្លូវគោក ធានាយ៉ាងពេញលេញដោយការធានារ៉ាប់រង និងអាចចូលទៅដល់ដោយផ្ទាល់ក្នុងកំពង់ផែក្រុងព្រះសីហនុ។

រ៉ូយ៉ាល់ រេលវេ កំពុងបន្តធ្វើបច្ចុប្បន្នភាព និងពង្រីកជួរនៃ សេវាកម្មរបស់ខ្លួន ដើម្បីបំពេញការពេញចិត្តរបស់អតិថិជនរបស់ខ្លួន។ រ៉ូយ៉ាល់ រេលវេ កំពុងវិនិយោគយ៉ាងខ្លាំងលើការកែលម្អក្បាលរថភ្លើង និងផ្លូវដែកនៃការដឹកជញ្ជូនទំនិញ និងសេវាកម្ម ដើម្បីបង្កើនភាពងាយស្រួលនៃការប្រើប្រាស់ និងដើម្បីឱ្យអតិថិជនជឿជាក់លើសេវាកម្មរបស់យើង។

### ២. ការវិភាគទៅលើការប្រែប្រួលនៃតម្លៃវត្ថុធាតុដើម

រ៉ូយ៉ាល់ រេលវេ កំពុងដំណើរការជាប្រតិបត្តិករផ្លូវដែកដើម្បីផ្តល់សេវាកម្មដឹកជញ្ជូនតាមរថភ្លើងដល់អតិថិជន ដូច្នេះការវិភាគនៃការប្រែប្រួលតម្លៃនៃវត្ថុធាតុដើមគឺមិនអាចអនុវត្តចំពោះក្រុមហ៊ុនបានទេ។

### ៣. ការវិភាគទៅលើពន្ធ

រ៉ូយ៉ាល់ រេលវេ មានកាតព្វកិច្ចបង់ពន្ធ និងអាករនានាជូនរដ្ឋ ក្រោមច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រ៉ូយ៉ាល់ រេលវេ គឺជាអ្នកជាប់ពន្ធធំ និងតម្រូវឱ្យបង់ពន្ធក្រោមប្រព័ន្ធពន្ធតាមរបបពិត ដូចដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ចំណាយពន្ធរួមមាន ពន្ធដែលបង់ក្នុងឆ្នាំសារពើពន្ធ និងពន្ធពន្យារ។ ចំណាយពន្ធត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### ៤. ការវិភាគទៅលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រុមហ៊ុនបានទទួល សេចក្តីជូនដំណឹងពី ន.ម.ក ថាការស្នើសុំត្រូវបានដាក់ជូន អ.ព.ដ។ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ ក្រុមហ៊ុនបានទទួលការឆ្លើយតបពី អ.ព.ដ ដើម្បីលើកលែងបំណុលពន្ធចំនួន ១.៨៤២.៩៧៣ ដុល្លារអាមេរិក។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ នេះ រ៉ូយ៉ាល់ រេលវេ រកបានប្រាក់ចំណូលសរុបប្រមាណ ១២.៧៣៦ លានរៀល កើនឡើងប្រមាណ០.១២% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ប្រាក់ចំណេញសុទ្ធបានកើនឡើងពីខាត -១.៥៥៥លានរៀលទៅចំណេញ ២.៥៥៣ លានរៀល។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ១. ហានិភ័យនៃអត្រាប្តូរប្រាក់

ក្រុមហ៊ុនប្រឈមមុខនឹងហានិភ័យនៃការផ្លាស់ប្តូររូបិយប័ណ្ណបរទេសដែលកើតចេញពីការទិញ និងប្រតិបត្តិការដែលត្រូវបានកំណត់ជារូបិយប័ណ្ណផ្សេងក្រៅពីរូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុនដែលជាប្រាក់រៀល។

រូបិយបណ្ណដែលបង្កើតហានិភ័យប្តូរប្រាក់បរទេសដល់ក្រុមហ៊ុនជាចម្បងគឺដុល្លារសហរដ្ឋអាមេរិក (USD) ពីការខ្ចីប្រាក់ និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ និងការទូទាត់ចំណាយប្រតិបត្តិការ។ ក្រុមហ៊ុនមិនការពារការប៉ះពាល់រូបិយប័ណ្ណបរទេសរបស់ខ្លួនទេ។ ដើម្បីគ្រប់គ្រងការប៉ះពាល់រូបិយប័ណ្ណបរទេសរបស់ខ្លួន គោលការណ៍របស់ក្រុមហ៊ុនគឺដើម្បីធានាថាការប៉ះពាល់សុទ្ធរបស់ខ្លួនត្រូវបានរក្សាទុកក្នុងកម្រិតដែលអាចទទួលយកបានដោយការទិញ ឬលក់រូបិយប័ណ្ណបរទេសក្នុងអត្រាការប្រាក់នៅពេលចាំបាច់។

### ២. ហានិភ័យនៃអត្រាការប្រាក់

ក្រុមហ៊ុនមិនកត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុក្នុងអត្រាថេរតាមតម្លៃសមស្របជា ចំណេញ ឬខាតទេ ហើយក្រុមហ៊ុនមិនមាននិស្សន្ទវត្ថុនាកាលបរិច្ឆេទរាយការណ៍របាយការណ៍។ ដូច្នេះ ការផ្លាស់ប្តូរនៃអត្រាការប្រាក់នៅចុងគ្រានាកាលបរិច្ឆេទរាយការណ៍របាការណ៍នឹងមិនប៉ះពាល់ដល់ចំណេញ ឬខាត។

## ខ. ផលប៉ះពាល់នៃអតិផរណា

- អតិផរណាជាផ្នែកមួយដ៏សំខាន់ណាស់សម្រាប់ រ៉ូយ៉ាល់ រលេវ ព្រោះប្រេងឥន្ធនៈគឺជាថ្លៃដើមចម្បងមួយនៃសេវាកម្ម។
- សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងមានការកើនឡើង ៦% ក្នុងឆ្នាំ២០២៣។
- ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ CPI ជាមធ្យម ២,៥% ក្នុងមួយឆ្នាំ។
- សេដ្ឋកិច្ចត្រូវបានគ្រប់គ្រងដោយដុល្លាជាធំ ហើយអត្រាប្តូរប្រាក់ប្រែប្រួលក្នុងកម្រិតទាបនៅក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ។
- នៅឆ្នាំ២០២៣ អត្រាអ្នកគ្មានការងារធ្វើរបស់កម្ពុជាត្រូវបានព្យាករណ៍ថានឹងមាននិន្នាការក្នុងរង្វង់ ២%។
- GDP របស់កម្ពុជាសម្រាប់ឆ្នាំ២០២៣ នឹងកើនឡើងដល់ ៥,៥% និង ៦,០% នៅឆ្នាំ ២០២៤ (ADB ខែមេសា ឆ្នាំ២០២៣)
- អត្រាអតិផរណារបស់កម្ពុជាត្រូវបានព្យាករណ៍ថានឹងនៅត្រឹម ៣% ក្នុងឆ្នាំ ២០២៣ និង ៤% ក្នុងឆ្នាំ ២០២៤ (ADO 2023)

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

- រាជរដ្ឋាភិបាលបានគ្រោងនឹងដាក់ឱ្យដំណើរការផែនការស្តារសេដ្ឋកិច្ចក្រោយកូវីដ-១៩ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ដោយផ្អែកលើវិធីសាស្ត្រ ៣ ការរស់រានមានជីវិត កំណែទម្រង់ និងភាពធន់។ ផែនការនេះផ្តោតលើការផលិតតម្លៃបន្ថែមទៅដល់វិស័យកសិកម្ម ផលិតកម្មក្នុងស្រុក (SME) ពាណិជ្ជកម្មអេឡិចត្រូនិក និងទេសចរណ៍។
- កម្ពុជាផ្តល់អាទិភាពលើការពង្រឹងប្រសិទ្ធភាពថវិកា។
- ការកែទម្រង់ការគ្រប់គ្រងពន្ធដារ ដែលបានបង្កើនចំណូលបន្ថែមតាមរយៈការពង្រឹងគោលនយោបាយពន្ធដារ។
- ពង្រឹងការធ្វើពិពិធកម្មមូលដ្ឋាននៃការប្រមូលចំណូល ដើម្បីធានានិរន្តរភាពនៃហិរញ្ញវត្ថុសាធារណៈ និងជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ច។

# ផ្នែកទី ៥ - ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

ភាពខ្លាំងរបស់ GuarantCo ចំពោះលទ្ធភាពនៃការទូទាត់សង៖

ក) GuarantCo មានកំណត់ត្រានៃការចាក់បញ្ចូលភាគហ៊ុនតាមកាលកំណត់ដែលផ្តល់ដោយម្ចាស់ភាគហ៊ុន ។.

ខ) GuarantCo គឺជាផ្នែកមួយនៃ PIDG ដែលមានទឹកប្រាក់ជាង ២,៤ ពាន់លានដុល្លារនៃមូលនិធិសរុប។

គ) GuarantCo មិនមានបំណុលនៅលើតារាងតុល្យការរបស់ខ្លួនទេ។

ឃ) ក្រុមប្រឹក្សាភិបាលអនុញ្ញាតឱ្យមានអានុភាពរហូតដល់ 3 ដងនៃភាគហ៊ុន និងដើមទុនដែលអាចប្រើបាន។

ង) Moody's និង Fitch ទាំងពីរមានស្ថេរភាពដោយក្រុមប្រឹក្សាភិបាល GuarantCo។

GuarantCo ត្រូវបានផ្តល់ចំណាត់ថ្នាក់ឥណទានដូចខាងក្រោម៖

| កម្រិត | ភ្នាក់ងារវាយតម្លៃឥណទាន | កាលបរិច្ឆេទ |
|---|---|---|
| AA- | FitchRatings | ខែឧសភា ឆ្នាំ២០២២ |
| A១ | Moody's | ខែមិថុនា ឆ្នាំ២០២២ |
| AAA | Parcra | ខែមិថុនា ឆ្នាំ២០២២ |
| AAA | Bloomfield Investment | ខែកញ្ញា ឆ្នាំ២០២១ |

បត្របំណុលធានាដោយ GuarantCo. អនុលោមតាម តាមលក្ខខណ្ឌនៃប័ណ្ណធានា (ដូចបានកំណត់ខាងក្រោម និងទម្រង់ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ខ) អ្នកធានាដោយគ្មានលក្ខខណ្ឌ និងមិនអាចដកហូតវិញបាន៖

- ការធានាដល់អ្នកតំណាងម្ចាស់មូលបត្របំណុល ធ្វើសកម្មភាពក្នុងនាមម្ចាស់ប័ណ្ណបំណុល ការទូទាត់ពេញលេញ និងពេញលេញដោយអ្នកចេញនូវចំនួនទឹកប្រាក់ធានា។
- ទទួលខុសត្រូវលើការផ្តល់សំណងដល់តំណាងម្ចាស់មូលបត្របំណុល ធ្វើសកម្មភាពក្នុងនាមម្ចាស់មូលបត្របំណុលតាមការទាមទារ ប្រឆាំងនឹងការបាត់បង់ណាមួយទាក់ទងនឹងចំនួនទឹកប្រាក់ធានាដែលរងទុក្ខដោយអ្នកតំណាងម្ចាស់មូលបត្របំណុល ធ្វើសកម្មភាពក្នុងនាមម្ចាស់បំណុល ប្រសិនបើកាតព្វកិច្ចណាមួយដែលធានាដោយអ្នកធានាគឺ ឬ ក្លាយជាមិនអាចអនុវត្តបាន មិនត្រឹមត្រូវ ឬខុសច្បាប់ដោយហេតុផលណាមួយ (មិនថាអ្នកធានា ឬអ្នកតំណាងម្ចាស់មូលបត្រ ដែលធ្វើសកម្មភាពក្នុងនាមម្ចាស់ប័ណ្ណបំណុលបានដឹងពីវា)។ ចំនួនទឹកប្រាក់នៃការបាត់បង់នេះជាចំនួនទឹកប្រាក់ដែលអ្នកតំណាងម្ចាស់មូលបត្របំណុលដែលធ្វើសកម្មភាពក្នុងនាមម្ចាស់ប័ណ្ណបំណុល បើមិនដូច្នេះទេ នឹងមានសិទ្ធិទទួលបានមកវិញក្រោមកថាខណ្ឌ ២ (ក) នៃប័ណ្ណធានា និងបានផ្តល់ សម្រាប់ការជៀសវាងការសង្ស័យថា ចំនួនទឹកប្រាក់ដែលត្រូវបង់ដោយអ្នកធានា មិនត្រូវលើសពីចំនួនធានាអតិបរមាក្នុងកម្រិតដែលអាចអនុវត្តបាន។ ហើយ (ដូចដែលបានកំណត់នៅក្នុងប័ណ្ណធានា) ស្របតាមលក្ខខណ្ឌនៃប័ណ្ណធានា រួមទាំងការជូនដំណឹងអំពីតម្រូវការទូទាត់ (ដូចបានកំណត់ក្នុងប័ណ្ណធានា) ចំពោះចំនួននេះត្រូវបានធ្វើឡើងចំពោះអ្នកធានាស្របតាម ទៅនឹងការធានា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃនៃសញ្ញាប័ណ្ណពីរដែលត្រូវបង់គឺ ៣៣.៨៨៨.៦៦៩ដុល្លារអាមេរិក (ស្មើនឹង៩០.២០០.០០០.០០០ រៀល) (នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖ គ្មាន)។ ក្នុងការិយបរិច្ឆេទ ក្រុមហ៊ុនបានធ្វើការបង្ករការប្រាក់ដែលត្រូវទូទាត់សងលើមូលបត្របំណុលដែលបានបោះផ្សាយដែលមានចំនួន ១៩៨.៦៤៣ដុល្លារអាមេរិក (ស្មើនឹង ៨១៦.៨២០.៥៨៧) (នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖ គ្មាន)។

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣

បានអាន និងឯកភាព

អ្នកឧកញ៉ា គិត ម៉េង

ប្រធានក្រុមប្រឹក្សាភិបាល